សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សិទ្ធិមនុស្សតាមទស្សនៈព្រះពុទ្ធសាសនា និងការលូតលាស់សង្គមប្រជាធិបតេយ្យសេរីក្នុងផ្លូវអាណាចក្រ ។

www.hoksavann.org

ថ្ងៃទី២១ មីនា ២០១១



ព្រះសម្មាសម្ពុទ្ធជាកំពូលនៃអ្នកគោរពសិទ្ធិមនុស្ស មិនតែប៉ុណ្ណោះព្រះអង្គបានណែនាំឲ្យមនុស្សគោរពសិទ្ធិមនុស្សនេះផង ។ លើសពីនេះទៅទៀត ព្រះអង្គបានណែនាំឲ្យគេគោរពជីវិតទូទៅ មានជីវិតសត្វតិរច្ឆានជាដើម ដូចជាធម៌បាណាក្នុងសិក្ខាបទទី១នៃសីល៥ជាដើម ។ ព្រះអង្គពន្យល់ថា មនុស្សនិងសត្វមានជីវិតមួយដូចគ្នា ស្រឡាញ់ជីវិត គឺមានជីវិតសញ្ញាដូចគ្នា ខុសគ្នាតែត្រង់គុណធម៌ប៉ុណ្ណោះ ។ ព្រះពុទ្ធបានប្រកាសប្រាប់ពិភពលោកឲ្យគោរពសិទ្ធិមនុស្សនេះកន្លងទៅជាង២៥៥០ឆ្នាំមកហើយ ចំណែកអង្គការសហប្រជាជាតិទើបតែប្រកាសឲ្យមនុស្សគោរពសិទ្ធិមនុស្សនៅថ្ងៃ១០ ធ្នូ ១៩៤៨នេះទេ ។ អង្គការសហប្រជាជាតិបានសំរេចចាត់ទុកបុណ្យពិសាខបូជារបស់ព្រះពុទ្ធសាសនាជាបុណ្យអន្តរជាតិ ដោយព្រះពុទ្ធសាសនាកើតមុនសាសនាដទៃ ហើយព្រះពុទ្ធសាសនាបង្រៀនកុំឲ្យមនុស្សបៀតបៀនគ្នា គឺធម៌អហឹង្សា ដែលជាមូលដ្ឋាននៃសន្តិភាពពិភពលោក ។

តាមព្រះពុទ្ធសាសនា ការរំលោភសិទ្ធិមនុស្ស គឺការធ្វើឲ្យមនុស្សទទួលការឈឺចាប់ដែលបណ្តាលមកពីការប្រព្រឹត្តពុំគប្បីពីបុគ្គលណាម្នាក់ ឬពីសំណាក់អាជ្ញាធររដ្ឋាភិបាល ។ លើសពីនេះទៀត ព្រះពុទ្ធសាសនាមិនត្រឹមតែគិតពីមារយាទមិនល្អ មិនត្រឹមត្រូវរបស់បុគ្គលនិងសង្គមប៉ុណ្ណោះទេ ថែមទាំងគិតទៅដល់ការប្រព្រឹត្តរវាងមនុស្សជាមួយសត្វតិរច្ឆាន និងរវាងមនុស្សជាមួយធម្មជាតិផងដែរ ។ សិទ្ធិប្រែថា ផលសំរេច គឺជាអំណាចដែលធម្មជាតិបានផ្តល់ឲ្យតាំងពីកំណើតមក ។ ពាក្យថា សិទ្ធិមនុស្សមកពីសិទ្ធិនិងមនុស្ស ប្រែថាផលសំរេចរបស់សត្វដែលមានវិចារណញ្ញាណ បានដល់អំណាចដែលមានលទ្ធភាពអាចធ្វើឲ្យទៅជាមនុស្សពេញលក្ខណៈ ។ បានសេចក្តីថា សិទ្ធិមនុស្សគឺជាអំណាចរបស់មនុស្សដែលត្រូវតែទទួលស្គាល់នូវភាពថ្លៃថ្នូរ ដែលជាប់ពីកំណើត និងសិទ្ធិទាំងឡាយដែលមិនអាចដកហូតបានពីមនុស្សទាំងអស់ ។ សិទ្ធិដែលមិនអាចដកហូតបាន គឺជីវិត ការនិយាយស្តី ប្រាសចាកទារុណកម្ម មិនអាចលក់ដូរ កម្មសិទ្ធិឯកជនជាដើម ។ សិទ្ធិមនុស្សជាក្របខណ្ឌច្បាប់ធម្មជាតិ និងជាគ្រឹះនៃសេរីភាព សមភាព យុត្តិធម៌ សន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ក្នុងសង្គម និងក្នុងពិភពលោក ។

របបប្រជាធិបតេយ្យបានចាប់កំណើតឡើងតាំងពីបូរាណកាលនៅប្រទេសក្រិក ។ ប្រជាពលរដ្ឋនៃទីក្រុងអាថែននៃប្រទេសក្រិក ដំបូងបានផ្លាស់ប្តូរវេនគ្នាតែងច្បាប់ និងគ្រប់គ្រងភូមិស្រុករបស់ខ្លួន ។ លុះដល់ពេលក្រោយមក ប្រជាពលរដ្ឋកាន់តែមានចំនួនច្រើនឡើង ទើបគេជ្រើសរើសតំណាងឲ្យធ្វើការជំនួសវិញ ហៅថាតំណាងប្រជាពលរដ្ឋ ហើយជ្រើសរើសអ្នកមានសមត្ថភាពម្នាក់ឲ្យដឹកនាំសង្គម ហៅថាប្រធានាធិបតី ។ លុះសម័យក្រោយមក គេសិក្សាយកគោលគំនិតនេះខ្លះ មកឆ្លៃរចនាលទ្ធិប្រជាធិបតេយ្យនេះឲ្យល្អប្រណីតឡើង តាមការយល់ឃើញនៃសង្គមប្រជាធិបតេយ្យសេរីរបស់ខ្លួន ។ អ្នកមានប្រជាធិបតេយ្យ គឺទទួលស្គាល់នូវកិត្តិយស នូវផលប្រយោជន៍ នូវសេរីភាពរបស់បុគ្គលម្នាក់ៗ ។ គឺសេរីភាពនេះហើយដែលមានលទ្ធភាពអាចសំរេចនូវទិសដៅរបស់ខ្លួនក្នុងសង្គម ។ សេរីភាពជាគន្លឹះនៃការជឿនលឿនគ្រប់វិស័យ មានវិស័យសេដ្ឋកិច្ច និងវប្បធម៌ជាដើម នេះដោយសារអ្នកប្រជាធិបតេយ្យទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលម្នាក់ៗ ដែលគេពុំអាចរំលោភបាន ។ ការអនុវត្តន៍នៃលទ្ធិប្រជាធិបតេយ្យសេរី គឺប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងប្រជាពលរដ្ឋ និងអ្នកដឹកនាំប្រទេសមានអំណាចឈរឈ្មោះឲ្យគេជ្រើសរើស មានអំណាចទិះតៀននយោបាយអ្នកដឹកនាំ មានអំណាចដកហូតអ្នកដឹកនាំដែលប្រព្រឹត្តផ្ទុយអំពីប្រយោជន៍ជាតិ ។ សង្គមប្រជាធិបតេយ្យសេរីបានចែកអំណាចទាំងបីឲ្យដាច់ចេញពីគ្នា មានលក្ខណៈឯករាជ្យរៀងខ្លួន គឺអំណាចនីតិបញ្ញត្តិ បានដល់សភាជាតិនិងព្រឹទ្ធសភា, អំណាចនីតិប្រតិបត្តិបានដល់រដ្ឋាភិបាល និងអំណាចតុលាការ ដើម្បីការពារយុត្តិធម៌ ។ ភាពឯករាជ្យរបស់តុលាការជាកត្តាសំខាន់ណាស់របស់សង្គមប្រជាធិបតេយ្យសេរី ព្រោះវាជាធាតុនៃយុត្តិធម៌និងធ្វើឲ្យសង្គមមានស្ថេរភាព បើសង្គមគ្មានយុត្តិធម៌ទេ ជាសង្គមគ្មានលំនឹងប្រកបដោយការចលាចល មានការរំលោភសិទ្ធិនិងបំពានច្បាប់ ។

របបកុម្មុយនិស្តពុំមានប្រជាធិបតេយ្យទេ ព្រោះរបបនេះប្រើអំណាចកាប់សម្លាប់ប្រជាពលរដ្ឋតាមអំពើចិត្ត ដោយគ្មានតុលាការជំនុំជំរះឡើយ ដកហូតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងបង្ខំឲ្យធ្វើការដូចទាសករ ដែលគេហៅថាអំណាចផ្តាច់ការនៃវណ្ណៈអធន ។ យើងអាចសង្ខេបជាគោលៗនៃលទ្ធិកុម្មុយនិស្តគឺ ប្រជាពលរដ្ឋគ្មានសិទ្ធិជ្រើសរើសមេដឹកនាំរបស់ខ្លួន មានគណបក្សតែមួយ គឺគណបក្សកុម្មុយនិស្ត អ្នកដឹកនាំស្ថិតនៅលើតែមនុស្សម្នាក់ឬមនុស្សមួយក្រុមតូច ដែលហៅថាអង្គការឬមជ្ឈិមបក្ស សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋត្រូវលុបចោលទាំងអស់ ។ ចំណែករបបផ្តាច់ការក៏ពុំមានប្រជាធិបតេយ្យដែរ ព្រោះរបបនេះការពារអំណាចរបស់ខ្លួនដោយប្រើអាវុធ ប្រើអំពើហឹង្សា ដើម្បីបំបិទមាត់ប្រជាពលរដ្ឋនិងគណបក្សណា ដែលប្រឆាំងជំទាស់នឹងនយោបាយរបស់ខ្លួន ។ អំណាចតុលាការមានការលំអៀងទៅបំរើជនផ្តាច់ការ ។ សិទ្ធិធ្វើកូដកម្មបាតុកម្មបានត្រូវបិទ បើហ៊ានធ្វើគេនឹងបង្ក្រាបដោយចុងកាណុង ដោយដំបងឆក់ រហូតដល់បាញ់សម្លាប់ ។ ក្រៅពីនេះអ្នកសារពត៌មានខ្លះដែលប្រឆាំងនឹងភាពខុសឆ្គងរបស់រដ្ឋាភិបាល បានត្រូវលួចបាញ់សម្លាប់ ឬឲ្យឡានដេញបុក ឬក៏ចោទឡើង

តុលាការ ។

របបផ្តាច់ការដែលកាន់អំណាចយូរ ដែលនៅសេសសល់ ក៏ត្រូវប្រជាពលរដ្ឋដេញចេញពីអំណាចជាបន្តបន្ទាប់គ្នា ។ ពេលថ្មីៗនេះ ប្រធានាធិបតីនៃប្រទេសទុយណេស៊ីនិងប្រទេសអេហ្ស៊ីប បានត្រូវប្រជាពលរដ្ឋរបស់ខ្លួនដេញចេញពីតំណែង ។ ចំណែកប្រធានាធិបតីនៃប្រទេសលីប៊ី ប្រទេសយេម៉ែន ស្រទេសស៊ីរី ក៏ប្រជាពលរដ្ឋរបស់ខ្លួនកំពុងធ្វើបាតុកម្មដេញចេញពីតំណែងដែរ ។ ចលនាអំណាចប្រជាពលរដ្ឋនេះអាចរាលដាលមកដល់ទ្វីបអាស៊ី បើអ្នកកាន់អំណាចនៅតែរំលោភសិទ្ធិប្រជាពលរដ្ឋ ធ្វើឲ្យខូចប្រយោជន៍ប្រជាពលរដ្ឋ ធ្វើឲ្យប្រជាពលរដ្ឋក្តៅក្រហាយ ។ អ្នកកាន់អំណាចផ្តាច់ការពោលថា គេនឹងបង្ក្រាបដោយអាវុធ បើប្រជាពលរដ្ឋធ្វើបាតុកម្មដេញពួកគេ ។ បើបង្ក្រាបដោយកម្លាំងអាវុធមានទ្រង់ទ្រាយធំ ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិនឹងចូលធ្វើអន្តរាគមន៍ស្របច្បាប់ ដើម្បីការពារប្រជាពលរដ្ឋ កុំឲ្យអ្នកកាន់អំណាចផ្តាច់ការសម្លាប់ ដូចនៅប្រទេសលីប៊ី នៅថ្ងៃទី២០មីនា២០១១ សម្ពន្ធភាព៥ប្រទេសនៃប្រទេសលោកខាងលិច ក្រោមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសន្តិសុខ បានចូលធ្វើអន្តរាគមន៍ ដោយបាញ់ផ្តោងរំលាយមូលដ្ឋានសឹករបស់លីប៊ី ទប់កុំឲ្យប្រធានាធិបតីផ្តាច់ការលីប៊ីសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនតទៅទៀត ។៚

❊ ❊

❊